**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ : ១២០៥ មស.ពសា

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការបោះពុម្ពតារាងទូទាត់បៀវត្ស អាណត្តិបើកប្រាក់ និងការបើកផ្ដល់ប្រាក់បៀវត្ស ជូនមន្ត្រីរាជការស៊ីវិលសម្រាប់ខែ មេសា-ឧសភា ឆ្នាំ២០១៨

យោងសារាចរលេខ ០១ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្ដីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្ដល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល ។

ក្រសួងមុខងារសាធារណៈ មានកិត្តិយស សូមគោរពជម្រាបជូនសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ឯកឧត្ដម លោកជំទាវអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត លោក លោកស្រីប្រធានមន្ទីរ និងអង្គភាពចំណុះមេត្តាជ្រាបថា ក្នុងគោលបំណងចូលរួមអនុវត្តឱ្យបានសម្រេចនូវខ្លឹមសារនៃសារាចរ ដូចមានយោងខាងលើ និងគោលការណ៍ថ្មីៗរបស់រាជរដ្ឋាភិបាល ឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងមុខងារសាធារណៈ សូមដាក់ចេញនូវសេចក្ដីជូនដំណឹងសម្រាប់សហការអនុវត្តដូចខាងក្រោម៖

- សម្រាប់បៀវត្សប្រចាំខែមេសា ឆ្នាំ២០១៨ ក្រសួងមុខងារសាធារណៈ សូមស្នើសុំគ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះ ពុំចាំបាច់សុំធ្វើការបម្រែបម្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារទេ លើកលែង ករណីផ្ទេរក្របខ័ណ្ឌ និងរៀបបៀវត្សមន្ត្រីថ្មី ដោយត្រូវផ្ដល់ឯកសារមកក្រសួងមុខងារសាធារណៈ យ៉ាងយូរត្រឹមថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ។
- ក្រសួងមុខងារសាធារណៈ នឹងរៀបចំបោះពុម្ពតារាងទូទាត់បៀវត្សខែមេសា ឆ្នាំ២០១៨ ដោយផ្អែកលើទិន្នន័យដែលមានក្នុងតារាងទូទាត់បៀវត្សរបស់មន្ត្រីរាជការស៊ីវិលប្រចាំខែមីនា ឆ្នាំ២០១៨ជាគោល និងធ្វើការរៀបចំទិន្នន័យមួយចំនួនទៀតជាស្វ័យប្រវត្តិទៅតាមគោលការណ៍ថ្មីរបស់រាជរដ្ឋាភិបាល ។
- គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវធានាការបើកផ្ដល់ប្រាក់បៀវត្សប្រចាំខែមេសា ឆ្នាំ២០១៨ ជូនមន្ត្រីរាជការស៊ីវិលរបស់ខ្លួន ឱ្យបានមុនថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ យ៉ាងយូរត្រឹមសប្ដាហ៍ទី២ នៃខែមេសា ឆ្នាំ២០១៨ ។
- សម្រាប់ការបើកផ្ដល់ប្រាក់បៀវត្សប្រចាំខែឧសភា ឆ្នាំ២០១៨ គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវស្នើសុំបម្រែបម្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារ មកក្រសួងមុខងារសាធារណៈ ត្រឹមសប្ដាហ៍ទី៣ នៃខែមេសា ឆ្នាំ២០១៨ ដើម្បីធានាការបើកផ្ដល់បៀវត្សជូនមន្ត្រីរាជការស៊ីវិលរបស់ខ្លួនឱ្យបានយ៉ាងយូរក្នុងសប្ដាហ៍ទី៣ នៃខែឧសភា ឆ្នាំ២០១៨ ។

ក្រសួងមុខងារសាធារណៈ សង្ឃឹមថា សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ឯកឧត្ដម លោកជំទាវអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត លោក លោកស្រីប្រធានមន្ទីរ និងអង្គភាពចំណុះ នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីជូនដំណឹងនេះ តាមការគួរ ។

ថ្ងៃសុក្រ ១៥រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៨
**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរនិងអង្គភាពចំណុះ
- ឯកសារ-កាលប្បវត្តិ

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh